# មជ្ឈមណ្ឌលវប្បធម៌ខ្មែរកម្ពុជាក្រោម

**KHMER KAMPUCHEA KROM CULTURAL CENTER IN CAMBODIA**

ផ្ទះលេខ៤៥៩ ផ្លូវលេខ១១២ ក្រុម១៩ ភូមិវិមានទ្រង់ សង្កាត់ក្រាំងធ្នង់ ខណ្ឌដង្កោ រាជធានីភ្នំពេញ

ទូរស័ព្ទលេខ: 012 48 11 61 / 011 97 85 83. E-mail: tharoyont@yahoo.com


លេខ: ៤៦/០៩ KKKCCC

## លិខិតអំពាវនាវ

**មជ្ឈមណ្ឌលវប្បធម៌ខ្មែរកម្ពុជាក្រោម** (KKKCCC) មានកិត្តិយស សូមជំរាបជូនបងប្អូនជនរួមឈាមខ្មែរ ពិសេសខ្មែរកម្ពុជាក្រោម ដែលកំពុងរស់នៅឯបរទេសទាំងអស់ឱ្យបានជ្រាបថា អង្គការ-សមាគមខ្មែរកម្ពុជាក្រោមនៅកម្ពុជាទាំង០៩ មានគំរោងរៀបចំកម្មវិធីចំនួន៣គឺ ***ទី១.*** វេទិកាតុម្ពូល និងវេទិកាសាធារណៈស្តីពីទុក្ខលំបាករបស់ខ្មែរកម្ពុជាក្រោមរយៈពេល៦០ឆ្នាំកន្លងមក។ ***ទី២.*** ពិធីបុណ្យរាប់បាត្រឧទ្ទិសកុសលជូនដល់វិញ្ញាណក្ខន្ធ នៃយុទ្ធជន-យុទ្ធនារីខ្មែរកម្ពុជាក្រោមដែលបានស្លាប់ក្នុងព្រឹត្តិការណ៍ក្រោកឡើងតស៊ូទាមទារសិទ្ធិសេរីភាព កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៧៦នៅឯដែនដីកម្ពុជាក្រោមជាខួបលើកទី៣៣។ ***ទី៣.*** ប្រារព្ធទិវាសិទ្ធិមនុស្សអន្តរជាតិ១០ធ្នូ ខួបលើកទី៦១ ដែលរៀបចំឡើងដោយខ្មែរកម្ពុជាក្រោម នៅរាជធានីភ្នំពេញ ដើម្បីបញ្ចេញនូវសកម្មភាពបង្ហាញអំពីទុក្ខលំបាកខ្មែរកម្ពុជាក្រោម ចែកជូនសាធារណៈជនជាតិ អន្តរជាតិឱ្យបានជ្រាប។ ក្នុងកម្មវិធីទាំងអស់នេះមានអញ្ជើញបណ្តាអង្គការជាតិ អន្តរជាតិ សារពត៌មានជាតិ និងអន្តរជាតិ ព្រមទាំងឥស្សរជនខ្មែរមួយចំនួន។ ហើយនៅក្នុងពិធីនោះ ក៏មានចែកជូនដល់អ្នកចូលរួមនូវព្រឹត្តិបត្រអង្គការស្ត្រីខ្មែរកម្ពុជាក្រោម និងផែនទីដែនដីកម្ពុជាក្រោម ព្រមទាំងឯកសារផ្សេងៗជាច្រើនទៀត។

បណ្តាពិធីទាំង៣ខាងលើ យើងមានគំរោងចំណាយចំនួន២,៥០០ដុល្លា (ពីរពាន់ប្រាំរយដុល្លាសហរដ្ឋអាមេរិច) ប៉ុន្តែយើងខ្ញុំស្នើសុំបងប្អូនជនរួមឈាមខ្មែរនៅបរទេសចំនួនត្រឹមតែ ១២០០ដុល្លា (មួយពាន់ពីររយដុល្លាសហរដ្ឋអាមេរិច) ប៉ុណ្ណោះ នៅខ្វះប៉ុន្មានគឺបងប្អូនខ្មែរកម្ពុជាក្រោមនៅភ្នំពេញជាអ្នកទទួលបន្ទុក ដើម្បីរួមចំណែកក្នុងការរៀបចំកម្មវិធី។

យើងខ្ញុំសង្ឃឹមថា បងប្អូនជនរួមឈាមខ្មែរ ពិសេសខ្មែរកម្ពុជាក្រោមដែលកំពុងរស់នៅឯបរទេសច្បាស់ជាមានសទ្ធាជ្រះថ្លា បរិច្ចាគថវិកាដើម្បីគាំទ្រកម្មវិធីខាងលើឱ្យប្រព្រឹត្តិទៅប្រកបដោយជោគជ័យ ដើម្បីជាឧត្តមប្រយោជន៍នៃខ្មែរកម្ពុជាក្រោមរបស់យើង។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៩

ជ.គណៈកម្មាធិការប្រតិបត្តិ

ប្រធាន

យន្ត ធារ៉ូ

សមាជិករដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា

***សូម*** លោក គីម សាគល នៅសហរដ្ឋអាមេរិច
លោក ថាច់ វ៉ើន នៅកាណាដា
លោក កៀង ឡឹម នៅសហរដ្ឋអាមេរិច
លោក សេនា នៅសហរដ្ឋអាមេរិច
លោក អរុណតី នៅបារាំង
មេត្តាជួយផ្សព្វផ្សាយដោយក្តីអនុគ្រោះ។